ព្រះរាជាណាចក្រកម្ពុជា

**តុលាការកំពូល** ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងព្រហ្មទណ្ឌ

លេខៈ១៣៩ **អាងនាមប្រជារាស្ត្រខ្មែរ**

ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ **តុលាការកំពូល**

**សាលដីកា**

លេខៈ ១០ បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៦

ចុះថ្ងៃទី២៥ខែមករាឆ្នាំ២០០៦ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅៈ

១- ឯកឧត្តម **ឃឹម ប៉ុណ្ណ** ប្រធាន

២- លោក ឈឹម ស៊ីផល ចៅក្រម

៣- លោក រឿល មួន ចៅក្រម

៤- លោក ប៉ែន សារឿន ចៅក្រមរបាយការណ៍

៥- លោក ម៉ុង មុន្នីចរិយា ចៅក្រម

ក្រឡាបញ្ជី

អ្នកស្រី សុផុន សុមានីកា

**តំណាងមហាអយ្យការ**

ឯកឧត្តម ជួន ស៊ុនឡេង អគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ ៦៣ "ជ" ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ១៣៩ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ របស់តុលាការកំពូល ។

**<u>ពិរុទ្ធ</u>:** រំលោភលើសេចក្តីទុកចិត្ត ប្រព្រឹត្តនៅសង្កាត់ផ្សារដេប៉ូ I ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ កាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៩ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោស តាមមាត្រា៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ជនជាប់ចោទឈ្មោះ ហ៊ុយ ម៉េង "ម្ចាស់បណ្តឹងសាទុក្ខ" ភេទស្រី អាយុ៥២ឆ្នាំ ជាតិខ្មែរ របររកស៊ី លក់ដូរ ទីលំនៅសព្វថ្ងៃផ្ទះលេខ១៦C, ផ្លូវលេខ១៨៨ សង្កាត់ផ្សារដេប៉ូ I ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ ឆាវ គឹក (ស) ម្តាយឈ្មោះ លាង គឹម (ស) ប្តីឈ្មោះ ឆាយ ហេង មានកូន ០៤នាក់ ។ ក្រៅឃុំ ។

-មេធាវី : លោក ហាក់ សៀកលី

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ អៀង ឡាយ "ចុងបណ្តឹងសាទុក្ខ" ភេទស្រី អាយុ៥២ឆ្នាំ ជាតិខ្មែរ របររកស៊ី លក់ដូរ ទីលំនៅសព្វថ្ងៃផ្ទះលេខ១៦C ផ្លូវលេខ១៨៨ ក្រុម៣៣ សង្កាត់ផ្សារដេប៉ូ I ខណ្ឌទួលគោក ក្រុងភ្នំពេញ ។ បានផ្ទេរសិទ្ធិអោយឈ្មោះ គីម ហួយ ភេទស្រី អាយុ៣៤ឆ្នាំ ជាតិខ្មែរ មានទីលំនៅ៧៣E₀ ផ្លូវ១៧២ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

-មេធាវី : លោក ឡុង ដារ៉ា

-តាមពាក្យបណ្តឹង ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០២ របស់ឈ្មោះ អៀង ឡាយ ប្តឹងពីឈ្មោះ ហ៊ុយ ម៉េង ហៅ តាំង អេង ពីបទៈ រំលោភលើសេចក្តីទុកចិត្ត និង បទប្រមាថមើលងាយដោយហេតុថាៈ ឈ្មោះ ហ៊ុយ ម៉េង នេះបានបោកប្រាក់ពីខ្លួនចំនួន៣០.៥០០$US ដោយយល់ឃើញថា ផ្ទះខ្លួនជាប់លំនៅនឹងគ្នា ហើយមានការរាប់អានគ្នាផង ខ្លួនពុំបានអោយឈ្មោះ ហ៊ុយ ម៉េង ធ្វើកិច្ចសន្យា ឬ ផ្តិតមេដៃឡើយ គ្រាន់តែឈ្មោះនេះសន្យាផ្ទាល់មាត់ និង សរសេរលិខិតទទួលស្គាល់ថា បានជំពាក់ប្រាក់ និង ថ្ងៃ ខែ ឆ្នាំ ដែលជំពាក់តែប៉ុណ្ណោះ ។ ចាប់តាំងពីឈ្មោះ ហ៊ុយ ម៉េង បានខ្ចីប្រាក់ពីខ្លួន នៅលើកចុងក្រោយមក ឈ្មោះនេះពុំដែលបានសងឡើយ ហើយមិនត្រឹមតែប៉ុណ្ណោះ បានព្យាយាមគេចវេសពីផ្ទះរហូត ដោយពុំមានចេតនាសងឡើយ ។ ខ្លួនសុំទាមទារប្រាក់សំណងជម្ងឺចិត្តចំនួន ៥.០០០$US ( ប្រាំពាន់ដុល្លាអាមេរិក) ។

-បានឃើញដីកាសំរេចលេខ ៤១៩៩ ត.ព្រ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០២ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ បានសំរេច :

-លើកលែងចោទប្រកាន់លើឈ្មោះ ហ៊ុយ ម៉េង ហៅ តាំង អេង ភេទស្រី អាយុ៥២ឆ្នាំ ជាតិខ្មែរ កើតនៅសង្កាត់លេខ៥ ក្រុងភ្នំពេញ ទីលំនៅសព្វថ្ងៃផ្ទះលេខ១៦C ផ្លូវ១៨៨ សង្កាត់ផ្សារដេប៉ូI ខណ្ឌទួលគោក ក្រុងភ្នំពេញ មុខរបរលក់ដូរ ឪពុកឈ្មោះ ឆាវ តឹក (ស) ម្តាយឈ្មោះ លាង គីម (ស) ប្តីឈ្មោះឆាយ ហេង មានកូន០៤នាក់ ជាប់ចោទពីបទៈ រំលោភលើសេចក្តីទុកចិត្ត ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងអោយផ្តន្ទាទោសតាមមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៤២"ជ" ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០២ របស់អ្នកស្រី គីម ហ៊ួយ ផ្ទេរសិទ្ធិពី អៀង ឡាយ ប្តឹងមិនសុខចិត្ត នឹងដីកាសំរេចលេខ ៤១៩៩ ត.ព្រ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០២ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ លើដីកាទាំងមូល ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថា : រឿងនេះជនជាប់ចោទឈ្មោះ ហ៊ុយ ម៉េង មិនបង្ហាញការពិត ដោយកូនចេះសរសេរអក្សរចិន ចៅក្រមស៊ើបអង្កេតសរសេរអក្សរធំៗ ចំលើយអះអាងថា មិនចេះអក្សរចិន តែចេះអក្សរខ្មែរ គាត់មានចេតនាទុច្ចរិត មានល្បិចលួងលោមប្រាក់ច្រើន ហើយអំពើនេះ បង្ហាញពីចេតនាទុច្ចរិតជាអំពើឆបោក និង បង្វិលទៅតុលាការក្រុងភ្នំពេញដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៦៣"ជ" ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ:

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០២ របស់ឈ្មោះ គីម ហួយ ទុកជាត្រឹមត្រូវតាមទំរង់ នឹងគតិច្បាប់ ។

២-បដិសេធដីកាលើកលែងចោទប្រកាន់លេខ ៤១៩៩ ត.ព្រ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០២ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ ចោលជាអសារបង់ ។

៣-ចោទប្រកាន់ឈ្មោះ ហ៊ុយ ម៉េង ហៅ តាំង អេង ភេទស្រី អាយុ៥២ឆ្នាំ ទីលំនៅ នៅផ្ទះលេខ១៦C ផ្លូវលេខ១៨៨ ក្រុម៣៣ សង្កាត់ផ្សារដេប៉ូ I ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ មុខរបរ លក់ដូរ ឪពុកឈ្មោះឆាវ តឹក (ស) ម្តាយឈ្មោះលាង គឹម (ស) ប្តីឈ្មោះ ឆាយ ហេង មានកូន ០៤នាក់ ពីបទៈ ឆបោក ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៩ ។ បទល្មើសមានចែងនិង ផ្តន្ទាទោសតាមមាត្រា៤៥ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៤-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ៦៥ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៣ របស់សាលា ឧទ្ធរណ៍ទៅតុលាការក្រុងភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធី ។

៥-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខមេធាវី ប៊ុច វិច្ឆិកា ការពារជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី មេធាវី ឈិត បូរ៉ាវុធ ការពារអោយដើមបណ្តឹង កំបាំង មុខជនជាប់ចោទ ។

-បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ០៩ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៥ របស់លោក ប៊ុច វិច្ឆិកា ជាមេធាវីការពារអោយឈ្មោះ ហ៊ុយ ម៉េង ប្តឹងមិនសុខចិត្ត នឹងសាលដីកាព្រហ្មទណ្ឌលេខ៦៣"ជ" ចុះថ្ងៃ ទី១៣ ខែធ្នូ ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសារណាការពារ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៥ របស់ឈ្មោះ ហ៊ុយ ម៉េង

-បានឃើញសារណាតប ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៥ របស់ឈ្មោះ អៀង ធុំឡាយ

-បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា : ក្នុងរឿងនេះ មានកម្មវត្ថុទាំងរឿងរដ្ឋប្បវេណី និង រឿងព្រហ្មទណ្ឌ សាលាឧទ្ធរណ៍បានសំរេចចោទប្រកាន់ឈ្មោះ ហ៊ុយ ម៉េង ពីបទ ឆបោក ។ ជនជាប់ចោទ ហ៊ុយ ម៉េង បានខ្ចីប្រាក់ជារឿងកិច្ចសន្យាខ្ចី ត្រូវដោះស្រាយ តាមវិវាទរដ្ឋប្បវេណី មិនអាចកែប្រែបទល្មើស ព្រហ្មទណ្ឌបានទេ សូមបដិសេធសាលដីកាព្រហ្មទណ្ឌ លេខ៦៣"ជ" ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ចោលជាអសារបង់ ដោយឥតបង្វិល ។

-បានស្តាប់ក្រឡាបញ្ជីអានសារតាជាតិនិងសារណាការពាររបស់ជនជាប់ចោទឈ្មោះហ៊ុយ ម៉េង។

-បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះ គីម ហួយ នាពេលសវនាការថាៈ អ្នកស្រី ហ៊ុយ ម៉េង គឺជាអ្នកជិតខាង រាប់អានគ្នាជិតស្និត និងជញ្ជាំងផ្ទះជាប់គ្នា ជាមួយម្តាយនាងខ្ញុំ ការខ្ចីប្រាក់នេះមានចំនួន ១០លើក សរុបទាំងអស់ចំនួន ៣០.៥០០$US (បីម៉ឺនប្រាំរយដុល្លា)។ ម្តាយនាងខ្ញុំឱ្យគាត់ខ្ចីប្រាក់ដោយជឿលើសំដីអ្នកស្រី ហ៊ុយ ម៉េង ថា បើសិនគាត់ចង់បោកប្រាស់ ទោះជាមានស្នាមមេដៃច្រើនបែបណាក៏ដោយនៅតែបោកបានដែរ ។

+ហេតុអ្វីបានជាសរសេរអក្សរចិន?

ម្តាយក្មេកនាងខ្ញុំ អៀង ឡាយ ចេះអក្សរចិន និង ចេះនិយាយចិន ចំណែកអ្នកស្រី ហ៊ុយ ម៉េង ចេះនិយាយចិន តែមិនចេះសរសេរអក្សរចិនទេ ។ គាត់ខ្ចីគឺពុំបានឱ្យការប្រាក់ជារៀងរាល់ខែទេ ពេល៣ខែ ឬ ៥ខែ ក្រោយលក់ដីដាច់ ទើបយកមកសងទាំងដើមទាំងការ សរុបតែម្តង ។ ការខ្ចីប្រាក់គ្មានកិច្ចសន្យា មានតែកូនសៀវភៅសរសេរអក្សរចិនដែលជាវត្ថុតាង ។

<u>សំណូមពរៈ</u> - សុំតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការ

-សុំទាមទារទឹកប្រាក់ដែលជំពាក់ចំនួន៣០.៥០០$US និងជំងឺចិត្តចំនួន២០.០០០$US សរុបទាំងអស់ចំនួន ៥០.៥០០$US (ប្រាំម៉ឺនប្រាំរយដុល្លា) ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ហាក់ សៀកលី មេធាវីការពារជនជាប់ចោទ នាពេលសវនាការថាៈ ផ្តើមឡើងពីការប្តឹងទាមទារប្រាក់កំចី កាលពីថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៩ ចំនួន ១០.០០០$US (មួយម៉ឺនដុល្លា) និងថ្ងៃទី១០ ខែមករា ឆ្នាំ២០០០ ចំនួន ២០.៥០០$US (ពីរម៉ឺនប្រាំរយដុល្លា) តើពេលនោះបទល្មើសឆបោកបានកើតមានហើយ ឬ នៅ ?

+ក្រោយពីការស៊ើប និង សាកសួរសាក្សីឃើញថា ពុំមានភស្តុតាងគ្រប់គ្រាន់អាចដាក់បន្ទុក និងធ្វើការចោទ ទើបចៅក្រមស៊ើបអង្កេតចេញដីកាសំរេចលើកលែងចោទប្រកាន់លើកូនក្តីខ្ញុំបាទ ។

+ទាក់ទិន និងពាក្យបណ្តឹងគឺនិយាយពីការខ្ចីប្រាក់

+ភាគីទាំងពីរមានការព្រមព្រៀងរបស់គាត់

+សៀវភៅសរសេរអក្សរចិន គឺមានខ្ចីប្រាក់ចំនួនច្រើនលើក

+តាមការអះអាងរបស់គាត់គឺថា ការខ្ចីនេះ គ្មានគិតការប្រាក់ទេ

+កូនក្តីខ្ញុំបាទគឺគ្មានឈ្មោះ តាំង អេង ទេ

+តាមរបាយការណ៍នគរបាលក៏បានបញ្ជាក់ថា ការខ្ចីប្រាក់នេះ យើងស្តាប់ពុំបានច្បាស់ទេ តែយល់ថា គាត់មានលុយទិញដី សាងសង់ផ្ទះ ។

+លោក ឈិត បូរ៉ាវុធ មេធាវីការពារឱ្យដើមបណ្តឹងឈ្មោះ អៀង ឡាយ បានទទួលស្គាល់ថា មិនដែលមានបទអាជ្ញាទេ ។ ជាករណីរឿងរដ្ឋប្បវេណី ដោយកូនចំណុលប្រកែក ទើបប្តឹងពីបទ

ព្រហ្មទណ្ឌមួយទៀត ។

+ សាក្សីគឺជាកូនរបស់ដើមបណ្តឹងទាំងអស់

+ ការនិយាយនៅក្នុងអង្គហេតុមានការភន្តច្រឡំទាំងអស់

+ សាលាឧទ្ធរណ៍យកកំណត់ហេតុក្នុងរឿងរដ្ឋប្បវេណី ដោយយកចម្លើយទាំងនោះមកធ្វើជាភស្តុតាងដាក់បន្ទុក ។ ខ្ញុំបាទសូមបដិសេធនូវចម្លើយទាំងនេះ ។

+ តើរឿងនេះមានធាតុផ្សំនៃបទល្មើសដែរ ឬ អត់ ?

+ តាមមាត្រា ៤៥ សំអាងហេតុទាំងអស់គឺពុំមានធាតុផ្សំគ្រប់គ្រាន់ទេ មានលក្ខណៈផ្ទុយគ្នា ។

<u>សំណូមពរ</u>: សូមសំរេចដោយឥតបង្វិល និង តម្កល់ដីកាលើកលែងចោទប្រកាន់របស់កូនក្តីខ្ញុំបាទ ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ឡុង ដារ៉ា មេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី នាពេលសវនាការថា : រឿងខ្ចីប្រាក់គឺជារឿងកិច្ចសន្យា ។

+ កិច្ចសន្យាធ្វើឡើងដោយការសរសេរជាអក្សរចិន នៃកូនប្រុសស្រីទាំងពីររបស់ជនជាប់ចោទ ។

+ ផ្អែកតាមក្រឹត្យលេខ៣៨ ការខ្ចីប្រាក់ជារឿងកិច្ចសន្យា មិនអាចមកប្តឹងជារឿងព្រហ្មទណ្ឌបានទេ ប៉ុន្តែខ្ញុំបាទសូមបញ្ជាក់ថា អ្នកខ្ចីនៅតាមផ្សារជួនមានពេលខ្លះ មិនបានមានកិច្ចសន្យាគ្រប់ពេលតាមកាលៈទេសៈនោះទេ ខ្លះខ្ចីលុយ ១០០០ដុល្លា ដោយមាត់ទទេ ។

+ ធាតុផ្សំសត្យានុម័តគឺពាក់ព័ន្ធជុំវិញមានភស្តុតាងកូនបង្កើតរបស់ ហ៊ុយ ម៉េង បានសរសេរទឹកប្រាក់ជាអក្សរចិនផ្ទាល់នៅលើកូនសៀវភៅរបស់ជនរងគ្រោះ ។

+ មានវត្ថុតាងកូនសៀវភៅសរសេរអក្សរចិនដែលមានឈ្មោះអ្នកខ្ចី ចំនួនទឹកប្រាក់ និងកាលបរិច្ឆេទត្រឹមត្រូវ ។

+ មានកោសល្យវិច័យថា ពិតជាឈ្មោះអ៊ឹង ឈីវហ៊ួ និងអ៊ឹង ឈីវយ៉ុង បានរៀនអក្សរចិនប្រឡងជាប់វិញ្ញាបនប័ត្របឋមសិក្សាថ្នាក់ទី៦ ឆ្នាំទី២ ។

+ ជារឿងមុនអង្គសេចក្តី ត្រូវមានធាតុផ្សំអង្កេតបឋមរបស់តុលាការជាចំណុចសំខាន់ដើម្បីបង្វិលរឿងទៅវិញ ។

+ និយាយអំពីធាតុផ្សំតាមផ្លូវច្បាប់ គឺមានធាតុផ្សំគ្រប់គ្រាន់គ្រង់ :

-មានការគេចវេសពីលំនៅដ្ឋាន ( កូន១របស់គាត់រស់នៅភ្នំពេញទាំងអស់)

-តុលាការបានធ្វើការកោះហៅមួយលើក ពីរលើក យ៉ាងម៉េចក៏មិនចូល ដូច្នេះគំនិតទុច្ចរិតរបស់គាត់ គឺមានទុករួចទៅហើយ ហើយជនជាប់ចោទរូបនេះមានឈ្មោះហៅបី: ១-ឈ្មោះ ហ៊ុយ ម៉េង, ២-ឈ្មោះ តាំង អេង, ៣-ឈ្មោះ យាយ គឿ ចាត់ទុកជាអំពើឆបោកប្រាក់ដមៃន ។

+ មានការលក់ដូរ រកស៊ីអ្វីមិនបានទំនាក់ទំនងជាមួយប្តីរបស់ខ្លួនទេ ។

<u>សំណូមពរ</u>: សុំតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការ ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា: ស្តាប់ការសន្និដ្ឋានរបស់មេធាវីទាំងពីរ គឺនិយាយតែរឿងខ្ចីប្រាក់ តុលាការកំពូលបានកាត់ច្រើនរឿងមកហើយ ចាត់ចូលក្នុងរឿងរដ្ឋប្បវេណីទាំងអស់ ។ សាលាឧទ្ធរណ៍បានចោទពីបទ ឆបោក គឺមានលក្ខណៈធ្ងន់ធ្ងរណាស់ ចំពោះគាត់មានគំនិតទុច្ចរិត ឬ មិនទុច្ចរិត គឺជារឿងរវាងគូភាគី ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណារបស់ជនត្រូវចោទ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី សេចក្តីសន្និដ្ឋានរបស់មេធាវីជនត្រូវចោទ និង មេធាវីដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ០៩ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៥ របស់លោក ប៊ុច វិច្ឆិកា ជាមេធាវីជនត្រូវចោទ ធ្វើឡើងក្នុងកំនត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា៦៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចបដិសេធដីកាលើកលែងចោទប្រកាន់លេខ៤១៩៩ ត.ព្រ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០២ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងចោល ហើយសំរេចចោទប្រកាន់លើឈ្មោះ ហ៊ុយ ម៉េង ពីបទ: ឆបោកប្រាក់នោះជាការភ័ន្តច្រឡំពីព្រោះថា ការដែលដើមបណ្តឹងរដ្ឋប្បវេណីប្តឹងថា ឈ្មោះ ហ៊ុយ ម៉េង បានខ្ចីប្រាក់ខ្លួនជាច្រើនលើក រហូតដល់ ៣០.៥០០ដុល្លា ហើយគេចវៀសមិនព្រមសងខ្លួននោះ ពុំមានឯកសារអ្វីជាមូលដ្ឋានច្បាស់លាស់ គួរឱ្យតុលាការពិចារណាបានឡើយ ហើយការសំអាងលើលិខិតដែលសរសេរជាអក្សរចិនថា ជាភស្តុតាងនោះ គឺពុំច្បាស់លាស់ដដែល ពីព្រោះពុំមានភស្តុតាងណាបញ្ជាក់ថា អក្សរចិននោះ អ្នកណាជាអ្នកសរសេរ ពុំមានអ្នកដឹងឮនិងទទួលខុសត្រូវនោះទេ ហើយបើសិនជាមានភស្តុតាងថា ឈ្មោះហ៊ុយ ម៉េង បានខ្ចីប្រាក់ក៏ជារឿងកិច្ចសន្យាខ្ចីដែរ ដែលពុំមែនជាបទអាជ្ញាទេ ។

-យល់ឃើញថា ពុំមានភស្តុតាងដាក់បន្ទុកណាមួយលើឈ្មោះ ហ៊ុយ ម៉េង ថា បានប្រព្រឹត្តបទឆបោកតាមការប្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះឡើយ ហើយនាសវនាការនេះ ដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយថា ក្នុងរឿងក្តីនេះ អ្នកស្រីបានប្តឹងទារប្រាក់ទៅតុលាការរដ្ឋប្បវេណីហើយដែរ ដូចនេះគប្បីតុលាការពិចារណា និង សំរេចតាមការកំណត់នៃមាត្រា២២ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

-យល់ឃើញថា ការដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា រឿងនេះ ជារឿងមុន

អង្គសេចក្តីដែលគប្បីបង្វិលឱ្យចៅក្រមស៊ើបអង្កេត ធ្វើការស៊ើបអង្កេតដល់អង្គសេចក្តីនោះជាការពុំត្រឹមត្រូវទេ ពីព្រោះថា រឿងនេះចៅក្រមស៊ើបអង្កេតបានធ្វើការស៊ើបសួររួចរាល់ និងបានសំរេចលើកលែងចោទប្រកាន់រួចហើយដែរ ។

-យល់ឃើញថា ឈ្មោះហ៊ុយ ម៉េង បានធ្វើសារណាការពាររឿងក្តីរបស់ខ្លួនជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែមិនបានមកចូលរួមសវនាការនេះទេ ហើយមេធាវីឈ្មោះនេះក៏បានមកចូលរួមសវនាការនេះហើយដែរ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងកំបាំងមុខ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៦៣"ជ" ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ដែលសំរេចសេចក្តីមកនេះមានលក្ខណៈខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី

## កំបាំងមុខជនត្រូវចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ

១-ទទួលបណ្តឹងសាទុក្ខលេខ០៩ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៥ របស់លោក ប៊ិច វិច្ឆិកា ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ៦៣"ជ" ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ទាំងមូល ដោយឥតបង្វិល ។

៣-លើកលែងចោទប្រកាន់លើឈ្មោះ ហ៊ុយ ម៉េង ពីបទ ឆបោកប្រព្រឹត្តនៅផ្សារដេប៉ូ ៤ ខណ្ឌទួលគោក ក្រុងភ្នំពេញ កាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០២ ។

៤-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៥ ខែមករាឆ្នាំ ២០០៦ ។